**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

Ministry of Labour and Vocational Training

លេខ : ០១៦/២៥ ក.ប/ស.ជ.ណា.ម.ហ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន
## សម្រាប់ពលករជំនាញដើម្បីទៅធ្វើការនៅប្រទេសជប៉ុន

យោងតាមការជូនដំណឹងពីក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយស សូមជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងទៅធ្វើការនៅប្រទេសជប៉ុន ក្នុងប្រព័ន្ធពលករជំនាញឱ្យបានជ្រាបថា អង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន នឹងរៀបចំការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុនសម្រាប់ពលករជំនាញ តាមរយៈប្រព័ន្ធកុំព្យូទ័រ (CBT) ដែលមានព័ត៌មានលម្អិតដូចខាងក្រោមៈ

| ល.រ | ប្រភេទតេស្ត | កាលបរិច្ឆេទធ្វើតេស្ត | មណ្ឌល | តម្លៃចុះឈ្មោះ |
|---|---|---|---|---|
| ១ | ផ្នែកសំណង់ | ថ្ងៃទី៨, ៩, ១៦, ១៨ និង២១ ខែឧសភា ឆ្នាំ២០២៥ | វិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ (EDI) | ៧ដុល្លារ |
| ២ | ផ្នែកកសិកម្ម | ថ្ងៃទី៨, ៩, ១៦, ១៨ និង២១ ខែឧសភា ឆ្នាំ២០២៥ | | ៣៣ដុល្លារ |
| ៣ | ផ្នែកថែទាំ | ថ្ងៃទី៨, ៩, ១៦, ១៨ និង២១ ខែឧសភា ឆ្នាំ២០២៥<br>ថ្ងៃទី៦, ៨, ៩, ១៧, ២០, ២២ និង២៧ ខែមិថុនា ឆ្នាំ២០២៥<br>ថ្ងៃទី២, ៦ ៨, ១១, ១៤ និង១៧ ខែកក្កដា ឆ្នាំ២០២៥ | | ១៤ដុល្លារ |
| ៤ | ភាសាជប៉ុន JFT-Basic | ថ្ងៃទី៦, ៨, ៩, ១៧, ២០, ២២ និង២៧ ខែមិថុនា ឆ្នាំ២០២៥<br>ថ្ងៃទី២, ៦ ៨, ១១, ១៤ និង១៧ ខែកក្កដា ឆ្នាំ២០២៥ | | ៣៦ដុល្លារ |
| ៥ | ផ្នែកការងារនៅភោជនីយដ្ឋាន | ថ្ងៃទី៦, ៨, ៩, ១៧, ២០, ២២ និង២៧ ខែមិថុនា ឆ្នាំ២០២៥<br>ថ្ងៃទី២, ៦ ៨, ១១, ១៤ និង១៧ ខែកក្កដា ឆ្នាំ២០២៥ | | ៣៣ដុល្លារ |



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- លក្ខខណ្ឌចុះឈ្មោះធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន គឺចាប់ពីអាយុ ១៧ឆ្នាំឡើងទៅ ដោយមិនគិតពីកម្រិតវប្បធម៌
- ព័ត៌មានអំពីមណ្ឌលសម្រាប់ធ្វើតេស្តមានដូចខាងក្រោម៖
  - ❖ វិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ (EDI)
    - • អាសយដ្ឋាន៖ ផ្ទះលេខ៩A ផ្លូវលេខ៣៧០ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
    - • លេខទូរសព្ទ៖ +855 12 937 168 / +855 16 862 868 / +855 15 729 123 / +855 12 269 768
- សេវានៃការចុះឈ្មោះធ្វើតេស្ត គឺបង់ជូនទៅអង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន
- ឯកសារចាំបាច់ដែលត្រូវយកមកជាមួយនៅថ្ងៃធ្វើតេស្ត៖
  - ❖ អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ឬបណ្ណបើកបរ
- សម្រាប់ព័ត៌មានលម្អិត និងការចុះឈ្មោះ សូមចូលទៅគេហទំព័រ https://ac.prometric-jp.com/testlist/ssw/index.html

បញ្ជាក់៖ កាលបរិច្ឆេទនៃការធ្វើតេស្តខាងលើនេះ អាចនឹងផ្លាស់ប្តូរអាស្រ័យទៅតាមស្ថានភាពជាក់ស្តែង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងចង់ចុះឈ្មោះធ្វើតេស្តភាសា និងតេស្តជំនាញទាំង ៥ផ្នែកខាងលើ ជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ១រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០២៥

រដ្ឋមន្ត្រី

ហេង សួរ

ចម្លងជូន៖

-សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា (ACRA)

-ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់

"ដើម្បីផ្សព្វផ្សាយ"

-ឯកសារ កាលប្បវត្តិ